រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ :.០២៧/០៤ របក អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារ ៩ខែ ឆ្នាំ២០០៤
# របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(២៥/១២/២០០៣-២៥/៩/២០០៤)

## I / សភាពការណ៍គ្រឿងញៀន :

### ក-ការផលិត ការដាំដុះ និង ការចរាចរ :

#### ១-កញ្ឆា :

តាមរយៈការបំផ្លាញពិនិត្យឃើញនៅក្នុងរយៈពេល៩ខែឆ្នាំនេះដំណាំកញ្ឆាមានដាំនៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ក្រចេះ កំពង់ចាម កំពង់ស្ពឺ និង តាកែវ ។ រូបភាពនៃការដាំដុះនៅតាមខេត្តជាប់ព្រំដែនភាគពាយ័ព្យនិងខេត្តតាមដងទន្លេមេគង្គ(ជាពិសេសគឺខេត្តក្រចេះ)ច្រើនដាំនៅតាមតំបន់ព្រៃជ្រៅ ។

#### ២-ថ្នាំញៀនសំយោគATS (**A**mphetamine **T**ype **S**timulants) :

ជាទូទៅថ្នាំញៀនសំយោគATS ដែលនិយមប្រើប្រាស់នៅកម្ពុជាគឺ មេតំហ្វេតាមីន(យ៉ាម៉ា) និង អ៊ិចស្តាស៊ី ។ មេតំហ្វេតាមីនបានហូរចូលមកតាមច្រកនៃខេត្តស្ទឹងត្រែងយ៉ាងគំហុក គ្រាន់តែ៣ករណីធំៗដែលសមត្ថកិច្ចក្រុងភ្នំ-ពេញ ខេត្តកំពង់ចាម និង ខេត្តក្រចេះ បង្ក្រាបបានក្នុងខែកញ្ញានេះមានដល់ទៅ **៦៣៦.២០០** គ្រាប់ ។ នេះជាចំនួនដ៏ច្រើនលើសលប់មិនធ្លាប់មាននៅកម្ពុជា ពោលគឺលើសពីចំនួនដែលរឹបអូសបានក្នុងរយៈ៥ឆ្នាំបើគិតពីឆ្នាំ១៩៩៩ដល់ឆ្នាំ២០០៣ ដែលការរឹបអូស ATS បានត្រឹមតែ **៤៩៦.៣៦០** គ្រាប់ប៉ុណ្ណោះ ។ ដោយឡែកការនាំចូលនូវប្រភេទអ៊ិចស្តាស៊ីភាគច្រើនគឺផ្ញើតាមកញ្ចប់ប្រៃសណីយ៍ពីក្រៅប្រទេសចូលមកកម្ពុជា ។ ទន្ទឹមនឹងការហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នេះ គឺនៅមានសញ្ញាជាច្រើនទៀតដែលបង្ហាញថា ក្រុមឧក្រិដ្ឋជនបរទេសកំពុងព្យាយាមប្រើប្រាស់កម្ពុជាធ្វើជាកន្លែងផលិត តាមរយៈការបញ្ជូនល្បាយមេ្សៅមេតំហ្វេតាមីនមកឱ្យក្រុមឧក្រិដ្ឋជន

នៅក្នុងស្រុកធ្វើការផលិតដោយកូនពុម្ពកែឆ្នៃតូចៗសំរាប់សង្កត់គ្រាប់ថ្នាំដោយដៃ ដើម្បីងាយស្រួលក្នុងការចល័តពីកន្លែងមួយទៅកន្លែងមួយ ។

## ៣-ហេរ៉ូអ៊ីន :

ជារួម កម្ពុជាពុំមានលទ្ធភាពផលិតហេរ៉ូអ៊ីនទេ ។ តំបន់ត្រីកោណមាស ទើបជាប្រភពដ៏សំខាន់ដែលក្រុមឧក្រិដ្ឋជនអន្តរជាតិនាំចូលមកកម្ពុជាដើម្បីនាំបន្តទៅប្រទេសអូស្ត្រាលី សឹង្ហបុរី តៃវ៉ាន់ ហុងកុង វៀតណាម តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ កំពង់ផែសមុទ្រនិងផ្លូវគោកនានា ។ ដូច្នេះខេត្តស្ទឹងត្រែងគឺជាចំណុចក្តៅនៃការហូរចូលហេរ៉ូអ៊ីនដូចគ្នានិងមេតំហ្វេតាមីនដែរ ។

## ៤-សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ :

កេតាមីន (Ketamine) ក៏ដូចគ្នានឹងហេរ៉ូអ៊ីនដែរគឺកម្ពុជាពុំមានលទ្ធភាពក្នុងការផលិតវាទេ ។ កេ-តាមីនជាសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងឧបសម្ព័ន្ធនៃច្បាប់ត្រួតពិនិត្យគ្រឿងញៀនក្នុងតារាងIII នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៧១ ។

ឆ្នាំ២០០១ ឧក្រិដ្ឋជនបរទេសធ្លាប់លបលួចនាំកេតាមីនប្រភេទគ្រាប់ចំនួន៩.៨៤៧គ្រាប់និងប្រភេទម្សៅចំនួន៥គ.ក្រ ឆ្លងកាត់កម្ពុជាតាមយន្តហោះឆ្ពោះទៅសឹង្ហបុរី ប៉ុន្តែត្រូវបានមន្ត្រីគយនៅព្រលានយន្តហោះអន្តរ-ជាតិភ្នំពេញរកឃើញ ។ ឆ្នាំបន្តបន្ទាប់មកទៀត យើងបានរកឃើញនូវកេតាមីនប្រភេទទឹក ដែលក្រុមឧក្រិដ្ឋជនបានធ្វើការដឹកជញ្ជូនតាមផ្លូវគោកឆ្ពោះទៅកាន់តំបន់ប៉ោយប៉ែត ។

ថ្មីៗនេះ ( ថ្ងៃទី០៧ខែកញ្ញាឆ្នាំ២០០៤) កេតាមីនចំនួន៦៣គីឡូក្រាមត្រូវបានរកឃើញនៅព្រលានយន្តហោះស៊ៀងកៃសិកនៃទីក្រុងតៃប៉ិប្រទេសតៃវ៉ាន់ ។ តៃវ៉ាន់បានប្រកាសថា ការចាប់បានកេតាមីនលើកនេះជាករណីធំស្ថិតក្នុងលំដាប់ថ្នាក់ទី៣ដែលធ្លាប់ចាប់នៅក្នុងព្រលានយន្តហោះស៊ៀងកៃសិក និងមានតំលៃប៉ាន់ស្មាន២,៦៤លានដុល្លារសហរដ្ឋអាមេរិក ។ ល្បិចក្នុងការលាក់មានលក្ខណៈប្លែកពីធម្មតា គឺអ្នករត់ពន្ធបានយកកេតាមីនទៅបង្កក ហើយយកទៅ ដាក់នៅក្នុងធុងសំរាប់ក្លាស្សេត្រីស្រស់ដឹកចេញពីប្រទេសថៃទៅកាន់តៃវ៉ាន់ ។

គេបានស្រាវជ្រាវរកឃើញបក្សពួករបស់ក្រុមរត់ពន្ធគ្រឿងញៀនលំដាប់ថ្នាក់អន្តរជាតិមួយក្រុមនេះ មាននៅតំបន់អាស៊ីអគ្នេយ៍ និងបានតាមដានដឹងថាកេតាមីនក្នុងចំនួនខាងលើមានប្រភពនាំឆ្លងកាត់កម្ពុជា ។

## ៥-សារធាតុគីមីផ្សំ :

ក្នុងចំណោមសារធាតុគីមីផ្សំជាច្រើនមុខដែលនាំចូលមកកម្ពុជា អគ្គលេខាធិការដ្ឋានបានកត់សំគាល់ឃើញ ថាអាស៊ីដស៊ុលផួរិច ត្រូវបាននាំចូលច្រើនជាងគេក្នុងមួយឆ្នាំៗរាប់ពាន់តោន ។ ក្រៅពីការប្រើប្រាស់អាស៊ីដ-ស៊ុលផួរិចក្នុងផលិតកម្មស្របច្បាប់ យើងបានរកឃើញថាមានការបង្វែរសារធាតុនោះទៅផ្សំចំរាញ់យកប្រេងម្រះព្រៅ ដែលនៅក្នុងប្រេងនោះមានផ្ទុកនូវសារធាតុ **សាហ្វ្រូល** ដែលជាសារធាតុគីមីផ្សំដ៏សំខាន់ក្នុងការផលិតគ្រឿង

ញៀន ។ **សាហ្វ្រូល** គឺជាសារធាតុដែលមានចែងនៅក្នុងតារាង I នៃតារាងឧបសម្ព័ន្ធ IV របស់ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។ ក្រៅពីនោះ នៅមានការប្រើប្រាស់អាសុីដសុីលផ្លូវិចដោយលួចលាក់ក្នុងការផ្សំចំរាញ់យក**មេទ្យាវីល្លិល្ងៀត** (ឈ្មោះគីមីប៉ៃកបេរីន) ដែលច្បាប់បានហាមឃាត់ ។

ដោយឡែក **អេហ្វេឌ្រីន** ដែលជាវត្ថុធាតុដើមទី១សំរាប់យកទៅផលិតជាATS ទោះកន្លងមកនៅមិនទាន់មានភស្តុតាងបង្ហាញថាមានប្រភពនាំចេញពីកម្ពុជា ប៉ុន្តែមានពិតមានថាក្រុមឧក្រិដ្ឋជនបានធ្វើសកម្មភាពដឹកជញ្ជូនឆ្លងកាត់ស្ទើរគ្រប់ប្រទេសនៅទូទាំងអាសុីអគ្នេយ៍ ។ ពិតមាននេះផ្តើមចេញពីការចាប់បាន Speudoephedrine ដ៏ធំបំផុតមួយ (៧៥០គ.ក្រ) នៅប្រទេសអូស្ត្រាលីកាលពីថ្ងៃទី៤ខែកញ្ញាឆ្នាំ២០០៣ ដែលមានមុខសញ្ញា៦នាក់ត្រូវបានឃាត់ខ្លួននៅអូស្ត្រាលី និង ៥នាក់ឃាត់ខ្លួននៅទីក្រុងភ្នំពេញ ។ សកម្មភាពនេះ ជាសកម្មភាពតែមួយរបស់ក្រុមរត់ពន្ធហេរ៉ូអុីនចំនួន២៤គ.ក្រ ដែលចាប់បាននៅកំពង់ផែក្រុងសុីដនីប្រទេសអូស្ត្រាលីកាលពីខែមករាឆ្នាំ២០០៣ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាននិងកំពុងយកចិត្តទុកដាក់សំរបសំរួលនិងជំរុញយន្តការត្រួតពិនិត្យចំពោះសារធាតុទាំងពីរខាងលើនេះ ដើម្បីបង្ការទប់ស្កាត់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននិងការបង្វែរទៅផលិតគ្រឿងញៀនខុសច្បាប់ ។

## គ-<u>ការប្រើបំពានគ្រឿងញៀន</u> :

ដោយសារក្រុមឧក្រិដ្ឋជននៅក្នុងស្រុកបែកគំនិតបំលែងភាពសុទ្ធនៃមេតំហ្វេតាមីន ដើម្បីធ្វើឱ្យបរិមាណនៃគ្រាប់ថ្នាំកើនឡើង និងមានតម្លៃថោកហើយសម្បូរ បានធ្វើឱ្យអ្នកប្រើប្រាស់មានការកើនឡើងយ៉ាងឆាប់រហ័ស ហើយអ្នកញៀនមួយចំនួនដែលពីមុនធ្លាប់ប្រើការ៉ហិត ក៏មានលទ្ធភាពបែរមកប្រើមេតំហ្វេតាមីនវិញ ។

ATS គឺជាប្រភេទគ្រឿងញៀនដ៏សំខាន់ ដែលកំពុងមានការប្រើប្រាស់បំពាននៅក្នុងប្រទេស ជាពិសេសក្នុងចំណោមយុវវ័យ / ពលករ / អ្នកបើករថយន្តតាក់សុី / កម្មកររោងចក្រ / កម្មករសំណង់និងលីសែងសុទ្ធតែជាក្រុមដែលងាយទទួលរងគ្រោះថ្នាក់បំផុត ។ ពិតមែនមិនទាន់មានតួលេខជាផ្លូវការប៉ុន្តែមានសន្ទស្សន៍បង្ហាញថាអ្នកញៀនមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ :

-ឆ្នាំ២០០១ អ្នកប្រើប្រាស់គ្រឿងញៀនមានចំនួន ៩២៨ នាក់ ។

-ឆ្នាំ២០០២ អ្នកប្រើប្រាស់គ្រឿងញៀនមានចំនួន ២.៧៥០ នាក់ ។

-ឆ្នាំ២០០៣ អ្នកប្រើប្រាស់គ្រឿងញៀនមានចំនួន ៤.៣៨៧ នាក់ ។

ក្រុមអ្នកវិភាគអន្តរជាតិបានអះអាងថា ចំនួនពិតប្រាកដនៃអ្នកប្រើប្រាស់គ្រឿងញៀនអាចស្មើនឹងដប់ដងនៃចំនួនដែលបានរាយការណ៍ ។ ដូច្នេះបើគិតតាមចំនួនអ្នកញៀនក្នុងឆ្នាំ២០០៣កន្លងទៅនេះគឺស្មើនឹង ៤៣.៨៧០នាក់ ។ ការកើនឡើងនៃចំនួនអ្នកញៀន កំពុងបង្កឱ្យមានការរីករាលដាលនូវបទល្មើសនានានៅក្នុងសង្គមដែលទាមទារឱ្យអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ស្ថាប័នមានសមត្ថកិច្ចនិងសង្គមសុីវិលត្រូវគិតគូរជាបន្ទាន់នូវវិធានការក្នុងការលើក

កំពស់ការយល់ដឹងជាសាធារណៈ អំពីគ្រោះថ្នាក់នៃគ្រឿងញៀននិងផលប៉ះពាល់នៅក្នុងសង្គម ។ ទន្ទឹមនោះ ក៏ត្រូវគិតគូរជាបន្ទាន់ផងដែរក្នុងការរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## II / <u>**លទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន**</u> :

ក្នុងរយៈពេល៩ខែឆ្នាំនេះ បណ្តាករណីដែលបង្ក្រាបបានមានចំនួន ១៨២ ករណី ចាប់បានជនល្មើស ចំនួន ៤២០ នាក់ ក្នុងនោះគឺ :

**១-<u>ករណីATS</u>** :

- ៩ខែឆ្នាំ២០០៣ ATSមាន ១៣០ ករណី / ជនល្មើស ២៩៧ នាក់ ដកហូតATS ១៣៥.៨៧៧ គ្រាប់ ។
- ៩ខែឆ្នាំ២០០៤ ATSមាន ១៧៥ ករណី (កើនឡើង ៤៥ ករណី) / ជនល្មើស ៤១២ នាក់ (កើនឡើង ១៥៥ នាក់) ដកហូតATS **៨២៩.១២៦** គ្រាប់ (កើនឡើង ៦៩៣.២៤៩ គ្រាប់) ។

បែងប្រភេទករណី :

**-ករណី ជួញដូរ** ATS : ១៥៩ ករណី, ជនល្មើស ៣១៧ នាក់ :

| | | | |
|---|---|---|---|
| -បញ្ជូនទៅតុលាការ | ជនជាតិខ្មែរ | សរុប ២៩៤ នាក់ (ស្រី៥១នាក់) ។ |
| | ជនជាតិវៀតណាម | សរុប ១៨ នាក់ (ស្រី ៦នាក់) ។ |
| | ជនជាតិឥណ្ឌា | សរុប ១ នាក់ (ប្រុស) ។ |
| | ជនជាតិថៃ | សរុប ១ នាក់ (ប្រុស) ។ |
| | ជនជាតិនីហ្សេរីយ៉ា | សរុប ១ នាក់ (ប្រុស) ។ |
| | ជនជាតិអង់គ្លេស | សរុប ១ នាក់ (ប្រុស) ។ |
| -អប់រំដោះលែង | ជនជាតិខ្មែរ | សរុប ១ នាក់ (ប្រុស) ។ |

-ដកហូត ATS **៨២៩.១២៦ គ្រាប់** និង ពុម្ពដែសង្កត់គ្រាប់ថ្នាំ ៣ គ្រឿង ។

**-ករណី ផលិត ATS** : ៣ ករណី, ជនល្មើស ៧ នាក់ :

-បញ្ជូនទៅតុលាការ ជនជាតិខ្មែរ ប្រុស ៦ នាក់ ។

-បញ្ជូនទៅតុលាការ ជនជាតិវៀតណាម ប្រុស ១ នាក់

-ដកហូតថ្នាំយ៉ាម៉ាពាកញ្ចប់តូច, ពុម្ពដែសង្កត់គ្រាប់ថ្នាំ៧, ដង្គុំគាប១, ជញ្ជីងថ្លឹង១, ម្សៅពិណសផ្ត្រាម, កញ្ឆាក្រៀម ១,៥០ គ.ក្រ ។

**-ករណី ប្រើប្រាស់ ATS** : ១៣ ករណី, ជនល្មើស ៨៨ នាក់ :

| | | |
|---|---|---|
| -បញ្ជូនទៅតុលាការ | ជនជាតិខ្មែរ | សរុប ២៦ នាក់ (ស្រី៤នាក់) ។ |
| | ជនជាតិវៀតណាម | សរុប ៤ នាក់ (ប្រុស) ។ |

-អប់រំដោះលែង ជនជាតិខ្មែរ សរុប ៥៨ នាក់( ស្រី៥នាក់) ។

**២-ករណី ហេរ៉ូអ៊ីន :**

- ៩ខែឆ្នាំ២០០៣ ករណីហេរ៉ូអ៊ីនមាន ៣ ករណី / ជនល្មើស ១០ នាក់ ដកហូតហេរ៉ូអ៊ីន ៩,២ គ.ក្រ ។
- ៩ខែឆ្នាំ២០០៤ ករណីហេរ៉ូអ៊ីនមាន ៣ ករណី / ជនល្មើស ២ នាក់ ដកហូតហេរ៉ូអ៊ីន ៥,១៥០ គ.ក្រ ។

-បញ្ជូនទៅតុលាការ ជនជាតិខ្មែរ សរុប ១ នាក់( ប្រុស) ។

ជនជាតិម៉ាឡេស៊ី សរុប ១ នាក់( ប្រុស) ។

**៣-ករណី កេតាមីន :** សរុប ៣ ករណី ចាប់បានជនល្មើសចំនួន ៦ នាក់ និងដកហូតកេតាមីនបាន ២៥១៥០ ដប ។

-បញ្ជូនទៅតុលាការ ជនជាតិខ្មែរ សរុប ៤ នាក់( ស្រី២នាក់) ។

ជនជាតិថៃ សរុប ២ នាក់( ស្រី) ។

**៤-ករណី អាស៊ីដស៊ុលផួរិច :** សរុប ១ ករណី (ជនល្មើសគេចខ្លួន) ដកអាស៊ីដស៊ុលផួរិច ២.៦២៤ គ.ក្រ ។

បណ្តាអង្គភាពអនុវត្តច្បាប់ដែលបានធ្វើកិច្ចប្រតិបត្តិការបង្ក្រាបរួមមាន :

| ឈ្មោះអង្គភាព | ករណី | ជនល្មើស (នាក់) | វត្ថុតាង | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ATS (គ្រាប់) | ហេរ៉ូអ៊ីន (គ.ក្រ) | កេតាមីន | |
| មន្ទីរប្រឆាំងគ្រឿងញៀន | ៦៥ | ១៨៩ | ៦១.៧៩៤ | ០,៩៥០ គ.ក្រ | ១.៨៧៥ ដប | ពុម្ពដែលសង្កត់គ្រាប់ថ្នាំ ៣ |
| នគរបាលក្រុងភ្នំពេញ | ៥៧ | ១២៥ | ៦២.៦៣២ | | ២៣.២៥០ ដប | ពុម្ពដែលសង្កត់គ្រាប់ថ្នាំ ៧ |
| នគរបាលក្រុងប៉ៃលិន | ៣ | ៥ | ៧៦ | | | |
| នគរបាលខេត្តស្ទឹងត្រែង | ៦ | ១០ | ២២.៦៩៧ | | | |
| នគរបាលខេត្តក្រចេះ | ៣ | ៤ | ៥៩១.៩២១ | ២,៤០០ គ.ក្រ | | |
| នគរបាលខេត្តកំពង់ចាម | ៣ | ៦ | ៣៦.៣៤៤ | | | |
| នគរបាលខេត្តសៀមរាប | ១១ | ២៥ | ១.២៩៦ | | | |
| នគរបាលខេត្តពោធិសាត់ | ១ | ២ | | | | |
| នគរបាលខេត្តកោះកុង | ៣ | ៥ | ២១២ | | | |
| នគរបាលខេត្តបាត់ដំបង | ១០ | ២៣ | ១១.៩៣៧ | | | |
| នគរបាលខេត្តបន្ទាយ/ជ័យ | ៥ | ៨ | ១.៦៣៥ | | | |
| នគរបាលខេត្តកណ្តាល | ៤ | ៣ | ៩៣១ | | | |
| **អ.ហ បន្ទាយមានជ័យ** | ២ | ២ | ១៧.១៤៥ | | | |
| **អ.ហ បាត់ដំបង** | ២ | ៣ | ៣.៣០៦ | | | |
| ប៉ូលីស អូស្ត្រាលី | ១ | ២ | | | | ករណីហេរ៉ូអ៊ីន២៤ គ.ក្រ |
| BLO ប៉ោយប៉ែត | ៣ | ៤ | ១៥.៤០០ | | ២៥ ដប | |

| | | | | | | |
|---|---|---|---|---|---|---|
| BLO +មន្ទីរ គ្រ.ញ | ១ | ៣ | ១.៨០០ | | | |
| BLO + គឃ បារិត | ១ | ០ | | | | អាស៊ីដស៊ុលផួរិច ២.៦២៤ គ.ក្រ |
| គយព្រលានយន្តហោះភ្នំពេញ | ១ | ១ | | ១,៨០០ គ.ក្រ | | |
| **សរុប ៩ខែ២០០៤** | **១៨២** | **៤២០** | **៨២៩.១២៦ គ្រាប់** | **៥,១៥០ គ.ក្រ** | **២៥.១៥០ ដប** | **អាស៊ីដស៊ុលផួរិច ២.៦២៤ គ.ក្រ** |

## ៥.លទ្ធផលបំផ្លាញដំណាំកញ្ឆា :

ក្នុងរយៈពេល៩ខែឆ្នាំនេះ ដំណាំកញ្ឆាដែលបានបំផ្លាញសរុបមានចំនួន ១៣.៦៧២ ម៉ែត្រក្រឡា ក្នុងនោះបំផ្លាញនៅ :

- ខេត្តបាត់ដំបង លើផ្ទៃដីចំនួន ១៩ ម៉ែត្រក្រឡា
- បន្ទាយមានជ័យលើផ្ទៃដីចំនួន ១.៨២៥ ម៉ែត្រក្រឡា
- សៀមរាបលើផ្ទៃដីចំនួន ១២៣ ម៉ែត្រក្រឡា
- ក្រចេះលើផ្ទៃដីចំនួន ៨.១២៨ ម៉ែត្រក្រឡា
- កំពង់ចាមលើផ្ទៃដីចំនួន ៣.៤៣៣ ម៉ែត្រក្រឡា
- កំពង់ស្ពឺលើផ្ទៃដីចំនួន ៦ ម៉ែត្រក្រឡា
- តាកែវលើផ្ទៃដីចំនួន ២៩ ម៉ែត្រក្រឡា

## ៦.លទ្ធផលនៃការត្រួតពិនិត្យសារធាតុគីមីផ្សំ :

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានពិនិត្យនៅក្នុងតារាងស្ថិតិសារធាតុគីមីផ្សំដែលក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់ឱ្យឃើញមានសារធាតុគីមីចំនួន១៧មុខ ដែលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ដូចមានរាយប្រភេទខាងក្រោម :

| ឈ្មោះសារធាតុគីមី | តោន | គីឡូក្រាម | លីត្រ | ប្រអប់ |
|---|---|---|---|---|
| Acetic Acid | ២២៤,១៩២ | | | |
| Acetone | ៩,១៣២ | | | |
| Sulphuric Acid | ២.៧០៧,៤១ | | | |
| Toluene | ១៣៣,៣៥១ | | | |
| Hydrochloric Acid | ៤១០,២៩ | | ៤៥.000 | |
| Methylbenzene | ២០ | | | |
| Methyl Ethyl Ketone | ៥ | | ៦00 | ៦៥ |
| Pseudoephedrine | | ៣00 | | |

| | | | | |
|---|---|---|---|---|
| Phenylpropanolamine Hydrochloride | | ១00 | | |
| Codein | | ២0 | | |
| Glacial Acetic Acid | ២៩៨,១១ | | | |
| Sodium Hypochloride | ៣៩,៨0 | | | |
| Ethyl Acetate | ១,៥0 | | | |
| Formic Acid | ៧,៥0 | | | |
| Trichloroethylene | ២0 | | | |
| Methylene Chloride | ៩0,៥0 | | | |
| -$H_2SO_4$ | ៤00 | | | |
| សរុប | ៤៣៦៦,៧៨៥ | ៤២0 | ៤៥.៦00 | ៦៥ |

ចំនួននេះ អាចមានតុល្យភាពគ្នាទៅនឹងតំរូវការប្រើប្រាស់ស្របច្បាប់ ។

## ៧~លទ្ធផលកោសល្យវិច័យវត្ថុតាង :

ក្នុងរយៈពេល៩ខែឆ្នាំនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើវត្ថុតាង ដែលបានបញ្ជូនមកពី មន្ទីរប្រឆាំងគ្រឿងញៀន, នគរបាលក្រុងភ្នំពេញ, ខេត្តកណ្ដាល, ស្វាយរៀង, ស្ទឹងត្រែង, កងរាជរាជអាវុធហត្ថ, តុលាការក្រុងភ្នំពេញ, តុលាការខេត្តបាត់ដំបង....សរុបបានចំនួន ៨៤ ករណី ។ លទ្ធផលបានបង្ហាញឱ្យឃើញនូវវត្តមាននៃសារធាតុ មេតំហ្វេតាមីន, មេតំហ្វេតាមីន+កាហ្វេអ៊ីន, មេតំហ្វេតាមីន+កេតាមីន, មេតំហ្វេតាមីន+ អេហ្វេឌ្រីន, កេតាមីន, កាហ្វេអ៊ីន, ប៉ារ៉ា+កេតាមីន, ប៉ារ៉ា+កាហ្វេអ៊ីន, អូផ្យូមអាល់កាឡូអ៊ីដ, ហេរ៉ូអ៊ីន, អ៊ិចស្តាស៊ី, ហេរ៉ូអ៊ីន, Tetra hydrocanabinol (THC), MDMA+កាហ្វេអ៊ីន ។

## ៨~ការងាររដ្ឋបាល និង នីតិកម្ម :

ក្នុងរយៈពេល៩ខែនេះ ដើម្បីរួមចំណែកក្នុងការងារបង្រ្កាបបទល្មើសធានាមានប្រសិទ្ធភាពខ្ពស់ អគ្គ-លេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងយុត្តិធិមបញ្ចប់នូវការធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបានពិភាក្សាជាមួយក្រុមប្រឹក្សាអ្នកច្បាប់របស់រាជរដ្ឋាភិបាលដោយផ្ចិតផ្ចង់បំផុត ដែលអាចនៅក្នុងអំឡុងចុងឆ្នាំសេចក្តីព្រាងច្បាប់នេះនឹងត្រូវបានរៀបចំបញ្ជូនទៅរដ្ឋសភា ។

ជាមួយគ្នានោះ ផែនការជាតិ៥ឆ្នាំ(២00៥-២0១0)ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ត្រូវបានឆ្លងការពិនិត្យនិងផ្តល់យោបល់ជាលើកចុងក្រោយបង្អស់ពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសមាជិក អ.ជ.ប.គ.ញ និងកំពុងរៀបចំបែបបទបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ ។

ដើម្បីពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីអនុវត្តច្បាប់ និងដោយមានការឧបត្ថម្ភគាំទ្រពី UNODC អគ្គលេខាធិការដ្ឋានបានបង្កើតបន្ថែមនូវ :

-មជ្ឈមណ្ឌលបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយកុំព្យូទ័រ នៅខេត្តសៀមរាប១កន្លែងទៀត (សរុបទាំងអស់មាន៤កន្លែង) និងបានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់គ្រប់ផ្នែកជំនាញសរុបចំនួន ៩៣៩ នាក់ ។

-មជ្ឈមណ្ឌលពិតមានគ្រឿងញៀន១កន្លែងនៅក្នុងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ព្រមជាមួយនឹងការបង្កើតឡើងនូវក្រុមការងារពិតមានគ្រឿងញៀនចំនួន៩ខេត្តក្រុងសំខាន់ៗគឺ ក្រុងភ្នំពេញ ក្រុងប៉ៃលិន ក្រុងព្រះសីហនុ ខេត្តកណ្តាល កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង កោះកុង សៀមរាប ដែលទិន្នន័យអ្នកប្រើបំពានគ្រឿងញៀនជំហានដំបូងដែលទទួលបានសរុបមានចំនួន ៤.០៨០ នាក់ ។

-ការិយាល័យទំនាក់ទំនងព្រំដែន(BLO)២កន្លែងទៀតនៅច្រកព្រំដែនក្អមសំណ និងប៉ុស្តិ៍សាខានៅជ្រៃធំ ។

ជាមួយនោះដែរ បណ្តាបទដ្ឋានច្បាប់នានាដែលពាក់ព័ន្ធទៅនឹងបញ្ហាគ្រឿងញៀនដូចជា :

-ប្រកាសរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលស្តីពី "ការគ្រប់គ្រងនិងត្រួតពិនិត្យការប្រើប្រាស់ នាំចូល នាំចេញ និង ចែក ចាយសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម" ។ និង

-សេចក្តីណែនាំរបស់អគ្គស្នងការនគរបាលជាតិស្តីពី " ផែនការស្រង់ស្ថិតិមុខសញ្ញាប្រព្រឹត្តបទល្មើសគ្រឿងញៀន " ត្រូវបានកំណត់ឱ្យអនុវត្តដើម្បីឈានទៅពង្រឹងយន្តការត្រួតពិនិត្យនិងតាមដានកាន់តែមានប្រសិទ្ធិភាព ។

ទន្ទឹមនោះ តាមកម្មវិធីរបស់ UNODC និងកិច្ចសហប្រតិបត្តិការជាមួយ JICA អគ្គលេខាធិការដ្ឋានបានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់គ្រប់ផ្នែកជំនាញរួមមាន នគរបាល គយ កាំកុងត្រូល....នៅក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកោះកុង តាកែវ និង កំពត អំពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និង ការត្រួតពិនិត្យសារធាតុគីមីផ្សំតាមឯកសារវីដេអូសរុបមាន ៨៥១ នាក់ ។

ក្រៅពីការងារខាងលើ នៅមានកិច្ចការសំខាន់ៗមួយចំនួនទៀតដូចខាងក្រោមគឺ :

-ពិធីប្រគល់ទទួលសំភារៈជំនួយរបស់អង្គការ JICA នូវម៉ាស៊ីនថតរូបចំនួន៤០គ្រឿង, ហ្វីលថតរូប៨០ដុំ និងឧបករណ៍សំរាប់ផលិត Test ១ចំនួន (១២/១២/០៣ ។

-កិច្ចប្រជុំបូកសរុបការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៣ និង ទិសដៅការងារឆ្នាំ២០០៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (២៤-២៥/២/២០០៤) ។

-ពិធីប្រគល់ម៉ាស៊ីនកុំព្យូទ័រ និង ព្រីនធ័រចំនួន៩គ្រឿង ដល់ក្រុមការងារប្រមូលទិន្នន័យនៃការប្រើបំពានគ្រឿងញៀនរបស់ ក្រុងភ្នំពេញ ក្រុងប៉ៃលិន ក្រុងព្រះសីហនុ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម កណ្តាល និង កោះកុង (១៩/៥/២០០៤) ។

-កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការស្វែងយល់ការពិតរបស់អន្តរសភាអាស៊ាន(៥-៩/៥/២០០៤) ។

-ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០០៤ ។

-កិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លើកទី៥ ដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការ៥ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០០៥-២០១០) ។

## ៩. ការកាត់បន្ថយតំរូវការគ្រឿងញៀន :

ដោយយល់ច្បាស់ថា គ្រឿងញៀនគឺជាមូលហេតុនៃការចម្លងមេរោគអេដស៍ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចុះអនុស្សារណៈ នៃការយោគយល់គ្នាជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (ចុះហត្ថលេខាថ្ងៃ៦/១/២០០៤) ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការយ៉ាងសកម្មជាមួយបណ្តាអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដូចជា : អង្គការឌីវ៉ក់ / អង្គការយេនឌ័រ / អង្គការសង្គមវិទ្យាកម្ពុជា / អង្គការស៊ីអ័រឌីណាស់ / អង្គការហ្វា / អង្គការពន្លឺសិល្បៈ / អង្គការរ៉ាក់ / អង្គការមូលនិធិគាំទ្រកុមារ / អង្គការយៃរ / មជ្ឈមណ្ឌលពិតមានស្ត្រីកម្ពុជា / មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម / អង្គការយុវសន្តិភាពនិងការិយាល័យយុវជន / អង្គការទស្សនៈពិភពលោក / កាកបាទក្រហមកម្ពុជា / វិទ្យុ-ទូរទស្សន៍ជាតិ និង ឯកជន / សិស្សានុសិស្សនៅតាមវិទ្យាល័យ និង អនុវិទ្យាល័យ...ដើម្បីចូលរួមជា :

-វាគ្មិន ក្នុងការបកស្រាយពន្យល់ចំពោះសំណួរ ចម្ងល់ទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ។

-បណ្តុះបណ្តាលដល់គ្រូបង្គោល, ជនបង្គោលតាមកម្មវិធី (មិត្តអប់រំមិត្ត) ។

-ការជជែកឆ្លើយឆ្លងតាមទូរស័ព្ទ ។ល។និង ។ល។ ដើម្បីចូលរួមចំណែកលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

ដោយយល់ឃើញថា ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក្នុងកាលៈទេសៈបច្ចុប្បន្ននេះគឺជាតំរូវការចាំបាច់ អគ្គលេខាធិការដ្ឋានបានបញ្ជូនមន្ត្រីទៅធ្វើទស្សនៈកិច្ចសិក្សានិងដកបទពិសោធន៍នៅប្រទេសថៃដើម្បីស្វែងយល់ពីរបៀបព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមវត្តអារាម និងរបៀបព្យាបាលដោយការប្រើឱសថបូរាណ ។ កម្មវិធីនេះអគ្គលេខាធិការដ្ឋាន បាននិងកំពុងសហការជាមួយក្រសួងធម្មការនិងសាសនា ដើម្បីជាបឋមយកវត្តសំរោងអណ្តែតធ្វើជាកន្លែងសំរាប់ព្យាបាល និងជាគំរូសំរាប់វត្តដែលមានលទ្ធភាពដទៃទៀត ។ ទន្ទឹមនោះ បានស្នើតាមរយៈក្រសួងធម្មការទៅសម្តេចព្រះសង្ឃរាជទាំង២គណៈ ដើម្បីបញ្ចូលការអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងនាទីធម្មទេសនានៃពិធីបុណ្យទានផ្សេងៗ ។

## ១០. កិច្ចសហប្រតិបត្តិការអន្តរជាតិ :

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបញ្ជូនមន្ត្រីទៅចូលរួមក្នុងសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, កិច្ចប្រជុំ, សន្និសីទ .....នៃបណ្តាគំរោងរបស់តំបន់ និង អន្តរជាតិនៅប្រទេសថៃ, វៀតណាម, ឡាវ, ជប៉ុន, អូស្ត្រាលី,

មីយ៉ាន់ម៉ា, ចិន, ម៉ាឡេស៊ី, សឹង្ហបុរី អំពីការងារកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន / ការកាត់បន្ថយតំរូវការគ្រឿងញៀន / ការងារអនុវត្តច្បាប់ និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។ល។ និង ។ល។ ដែលនៅក្នុងបណ្តាកិច្ចប្រជុំទាំងនោះមានកិច្ចការពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចខាងក្រោម :

-ខែ១១ឆ្នាំ២០០៤ កម្ពុជាត្រូវដល់វេនទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគី/ត្រីភាគីកម្ពុជា-វៀតណាម-ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

-ខែមេសាឆ្នាំ២០០៤បានចុះហត្ថលេខាលើគំរោងស្តីពីការគាំទ្រភាពជាដៃគូរនៃបណ្តាប្រទេស MOU នៅអាស៊ីបូពា ។

-ប្រទេសចិននឹងទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំក្រុមអ្នកជំនាញរៀបចំគំរោង(H15) នៅខេត្តយូណាន់ក្នុងខែវិច្ឆិកាឆ្នាំ២០០៤ ។

-ខែឧសភាឆ្នាំ២០០៤ បានចុះហត្ថលេខាលើគំរោងអនុតំបន់ស្តីពី កិច្ចសហប្រតិបត្តិការតំបន់ស្តីពីអភិវឌ្ឍន៍ការកែប្រែដោយយកសហគមន៍ធ្វើជាមូលដ្ឋាន ដើម្បីលុបបំបាត់ការផលិតអាភៀននៅអាស៊ីបូពា(AD/RAS/H84) ។

-ខែមិថុនាឆ្នាំ២០០៤ បានបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO)២កន្លែងបន្ថែមទៀតនៅច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ និងប៉ុស្តិសាខា១កន្លែងនៅជ្រៃធំ ។

-បានបញ្ជូនគំរោងស្នើសុំអ្នកជំនាញការជប៉ុនរយះពេលវែង១រូប សំរាប់ការងារអប់រំបង្ការ និង រយះពេលខ្លី៣រូបសំរាប់ការងារអនុវត្តច្បាប់ តាមរយះគំរោងជំនួយរបស់រាជរដ្ឋាភិបាលជប៉ុនសំរាប់ឆ្នាំ២០០៥ ។

-UNODC តំបន់បានឯកភាពតាមសំណើរបស់កម្ពុជា ដែលសុំឱ្យបញ្ចូលមេរៀនស្តីពីការប្រឆាំងនឹងការសំអាតប្រាក់កខ្វក់ ទៅក្នុងកម្មវិធី CBT ។

-UNODC តំបន់បានឯកភាពបន្តអាណត្តិនៃគំរោង AD/RAS/01/F97 រយះពេល២ឆ្នាំ៦ខែបន្ថែម ដើម្បីឱ្យការងារដែលនៅសេសសល់អាចអនុវត្តទៅបានពេញលេញ ។

-UNODC តំបន់បានទទួលយកទៅពិនិត្យនូវគំរោងស្តីពីការបង្កើតមជ្ឈមណ្ឌលព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងធ្វើការសំរេចនៅក្នុងអង្គប្រជុំ TASK-FORCE II ឆ្នាំក្រោយ ។

-ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ TASK-FORCE I នៃផែនការសកម្មភាព ACCORD អគ្គលេខាធិការដ្ឋានបានលើកគំរោងដែលមានឈ្មោះថា " ការលើកកំពស់សុខភាពតាមរយះកីឡាក្នុងចំណោមសិស្សសាលាក្នុងតំបន់ដែលងាយទទួលរងគ្រោះ" ដែលមានថវិកាប៉ាន់ស្មានចំនួន ២២.៧៥០ ដុល្លារ ស.រ.អា ដាក់ជូនUNODCតំបន់ពិនិត្យ ។

-ប្រទេសថៃទទួលធ្វើជាម្ចាស់ផ្ទះនិងជាប្រធាន, វៀតណាមជាអនុប្រធានសំរាប់កិច្ចប្រជុំនៅឆ្នាំ២០០៥ របស់ TASK-FORCE I ។

## III / **ទិសដៅប្រចាំត្រីមាសទី** IV **ឆ្នាំ២០០៤ :**

១-ត្រៀមលក្ខណៈសំរាប់កិច្ចប្រជុំត្រីភាគី/ទ្វេភាគី កម្ពុជា-វៀតណាម-ឡាវស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន លើកទី៤នៅរាជធានីភ្នំពេញ ( ១៦-១៩/១១/២០០៤) ។

២-រៀបចំបែបបទបញ្ជូនសេចក្តីព្រាងផែនការជាតិ៥ឆ្នាំ(២០០៥-២០១០)ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ។

៣-បន្តសហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់របស់រាជរដ្ឋាភិបាល ដើម្បីជំរុញការពិនិត្យពិចារណានិងរៀបចំបែបបទបញ្ជូនសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនទៅរដ្ឋសភា ។

៤-សហការជាមួយUNODC ត្រៀមរៀបចំកិច្ចដំណើរការស្ទាបស្ទង់ការបំពានគ្រឿងញៀន និង បញ្ហាហ៊ីវ/អេដស៍ នាចុងឆ្នាំនេះ ។

៥-យកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដែលបានដាក់ចេញ នៅក្នុងសម័យប្រជុំ អ.ជ.ប.គ.ញ លើកទី៥ ដូចខាងក្រោម :

ក-ពិចារណាក្នុងការបង្កើតឱ្យមានការិយាល័យប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមក្រសួងសមាជិក អ.ជ.ប.គ.ញ សំរាប់ធ្វើការងារត្រួតពិនិត្យគ្រឿងញៀន ទៅតាមជំនាញដែលពាក់ព័ន្ធនឹងក្រសួងខ្លួន ។

ខ-បង្កើតក្រុមការងារអន្តរក្រសួងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការងារព្យាបាលនិងស្តារនីតិសម្បទា ដើម្បីកសាងគោលនយោបាយថ្នាក់ជាតិស្តីពីការព្យាបាលនិងស្តារនីតិសម្បទា ជាពិសេសពិចារណាអំពីលទ្ធភាពក្នុងការជួយសំរបសំរួលដល់គំរោងការបង្កើតមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាមួយ ដោយដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរក្រុងភ្នំពេញ ។

គ-ត្រៀមរៀបចំកែសំរួលនូវ ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យបានសមស្របតាមសភាព-ការណ៍គ្រឿងញៀនជាក់ស្តែង ដើម្បីដាក់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិនិត្យនិងសំរេច ។

ឃ-ខិតខំឱ្យបានសំរេចនាចុងឆ្នាំនេះ ក្នុងការស្នើសុំផ្តល់សច្ចាប័នពីរដ្ឋសភាលើអនុសញ្ញាអន្តរជាតិទាំង៣ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ( ១៩៦១-១៩៧១-១៩៨៨) ។

៦-បន្តកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់តាមរយៈ ÷

-ការត្រួតពិនិត្យគ្រឿងញៀនដោយកុំព្យូទ័រ(CBT)

-ការត្រួតពិនិត្យសារធាតុគីមីផ្សំតាមឯកសារវីដេអូ

-ការស្វែងរកជំនួយដើម្បីបង្កើតមជ្ឈមណ្ឌល(CBT)មួយបន្ថែមទៀតនៅខេត្តកំពង់ចាម ។

៧-យកចិត្តទុកដាក់ជំរុញសកម្មភាពការងារ របស់ក្រុមការងារប្រមូលទិន្នន័យនៃការប្រើបំពានគ្រឿងញៀន នៅតាមខេត្តក្រុងទាំង៩គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងប៉ៃលិន ខេត្តកោះកុង បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និង កណ្តាល ។

៨-សហការជាមួយក្រសួងពិតមាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្កើនការអប់រំផ្សព្វផ្សាយដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈ ÷

-ប្រព័ន្ធ ផ្សព្វផ្សាយជាតិ និង ឯកជន (វិទ្យុ ទូរទស្សន៍ សារព័ត៌មាន) ។

-ធ្វើការផ្សព្វផ្សាយតាមរយៈយុទ្ធនាការឃោសនា នៅតាមសាលារៀន-រោងចក្រ-សហគ្រាស-រោងភាពយន្ត-មូលដ្ឋានសហគមន៍ រួមនឹងការបណ្តុះបណ្តាលគ្រូបង្គោលនៅតាមសាលារៀននិងអង្គការក្រៅរដ្ឋាភិបាល ។

៩-សហការជាមួយក្រសួងធម្មការនិងសាសនា ដើម្បីបំផុសដល់វត្តអារាមឱ្យជួយផ្តល់នូវទីកន្លែងសំរាប់ទទួលអ្នកញៀនគ្រឿងញៀនដែលស្ម័គ្រចិត្តចូលខ្លួនមកព្យាបាល ដែលជំហានដំបូងយកវត្តសំរោងអណ្តែត ដើម្បីពង្រីកឱ្យក្លាយជាវត្តគំរូសំរាប់វត្តដែលមានលទ្ធភាពដទៃទៀត ។

១០-បន្តជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិតាមរយៈ ការបញ្ជូនមន្ត្រីទៅចូលរួមនៅក្នុងកិច្ចប្រជុំនៃបណ្តាគំរោងរបស់ថ្នាក់តំបន់ និង អន្តរជាតិនានា ។

**អគ្គលេខាធិការ**

**ចំលងជូន :**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
ប្រធាន អ.ជ.ប.គ.ញ

-ក្រសួងសមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
( ជូនជ្រាបជារបាយការណ៍ )

-ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

-នាយកដ្ឋានបូកសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
( ជាសមត្ថកិច្ច )

-ឯកសារ-កាលប្បវត្តិ